




## ៥~ ស្រោចស្រព:

បើយើងដាំកូនម្នាស់នៅរដូវប្រាំង យើងត្រូវស្រោចទឹកពន្លិចរងក្រោយដាំរួច និងត្រូវស្រោចវារៀងរាល់១ខែម្តង រហូតដល់ភ្លៀងធ្លាក់។

## ៦~កាច់សំអាតខ្នែង:

ជាធម្មតាពូជម្នាស់ស្រុកយើងពុំសូវឃើញមានខ្នែងកូននៅពេលដើមម្នាស់ កំពុងលូលាស់ទេ ប៉ុន្តែយើងគួរតែត្រួតពិនិត្យមើលបើឃើញមានខ្នែងត្រូវកាច់ចេញ ដោយទុកតែដើមមេមួយប៉ុណ្ណោះដើម្បីអោយបានផ្លែធំ។

## ៧~ជំរុញផ្កា:

ដើមម្នាស់ អាចចាក់ថ្នស្អុយបានលុះ ត្រាតែវាមានដើមធំល្អដែលមានស្លឹកលើស ពី២០ឡើងទៅ។ យកថ្នស្អុយលេខ១ចំនួន ៣ខាំលាយជាមួយ ទឹក១ធុងចំណុះ២០លីត្រ រួចយកទឹកល្បាយនេះចាក់ចូលក្នុងបណ្តូលដើមម្នាស់ទាល់តែពេញ។ ជាធម្មតាល្បាយទឹកថ្នស្អុយ២០លីត្រ អាចចាក់បាន ៣រងប្រវែង២០ម៉ែត្រ។ ក្រោយចាក់ថ្នស្អុយរយៈពេល ៤



ខែ២០ថ្ងៃទើបម្នាស់ទុំអាចកាច់យកលក់បាន។




**អាចរកទិញកូនម្នាស់បានតាមរយៈ**

១- អ្នកស្រី **ងួន ង៉ាន់**, ស្រុក មោងឫស្សី ខេត្តបាត់ដំបង, ទូរស័ព្ទ: ០៩២ ១៥ ៨២ ៦៧

២- លោក **ប៉ុង ៣**, អ្នកដាំម្នាស់ស្រុកអង្គរជុំ ខេត្តសៀមរាប, ទូរស័ព្ទ: ០៩២ ១៧ ៥១ ៥៨

៣- លោក **មាស ស្តើង**,អ្នកដាំម្នាស់ស្រុកវ៉ារិន ខេត្តសៀមរាប, ទូរស័ព្ទ: ០៩២ ៨៧ ៤៧ ៣៩

៤- អ្នកស្រី **រឿន ហ៊ត់**, អ្នកដាំម្នាស់ភ្នំគូលែន ខេត្តសៀមរាប, ទូរស័ព្ទ: ០៩៩ ៥២ ២៨ ៩៧

**សំរបសំរួលដោយ**
**កម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ខេត្តសៀមរាប**
Facilitated by RED - Green Belt Siem Reap



# ភាពជោគជ័យ នៃការដាំម្នាស់



## ការណែនាំអនុវត្តន៍ជាក់ស្តែងជាជំហានៗដោយ:

អ្នកស្រី **ងួន ង៉ាន់**, កសិករដាំម្នាស់នៅឃុំព្រៃកជីក, ស្រុក មោងឫស្សី, ខេត្តបាត់ដំបង ទូរស័ព្ទ: ០៩២ ១៥ ៨២ ៦៧

# ដំណាំម្នាស់

## ១_ការរៀបចំរង:

យើងត្រូវភ្ជួរដីអោយបានស្អាត ទុកចោល ១សប្តាហ៍ បន្ទាប់មកកាយចង្អូរ ឬភ្ជួរឆ្នូតដែល មាន-បណ្តោយ២០ម៉ែត្រ និងចន្លោះចង្អូរប្រវែង ១ម៉ែត្រ រួចដាក់ជីអាចម៍គោតាមចង្អូរហើយ លប់ដីពីលើ។

## ២_ ការដាំម្នាស់

យើងដាំកូនម្នាស់ពីលើចង្អូរដែលដាក់ជីអាចម៍គោ ដែលមានចន្លោះពីគុម្ពមួយទៅគុម្ពមួយ ប្រវែងពី ៣ ទៅ ៤តឹក និងចន្លោះរង ប្រវែង ពី៦ ទៅ ៨តឹក។ យើងត្រូវកប់គល់កូនម្នាស់ចូលទៅក្នុងដីប្រមាណ ១តឹក។












## ៣_ ការសំអាតស្មៅ, ពូនគល់ និង ការគ្របរង:

ស្មៅចាប់ផ្តើមដុះក្រោយយើងដាំ រួចរយៈពេល១ខែ យើងត្រូវត្រួតពិនិត្យមើល បើឃើញថាមានស្មៅដុះកំពស់កូនម្នាស់ យើងចាំបាច់ត្រូវធ្វើការជំរះស្មៅចេញ រួចពូនរងនិងយកស្មៅងាប់ ឬ ដើមកន្ទ្រាំងខែត្រ ឬអង្កាមដាក់ពីលើរងអោយបានច្រើនដើម្បីអោយកើតជាជី និងបន្ថយការលូតលាស់របស់ស្មៅ។

## ៤_ ការដាក់ជី:

- <u>ការដាក់ជីទ្រាប់បាត:</u> យើងដាក់ជីលាមកសត្វប្រមាណ៣ការុង ឬ៣០គីឡូក្រាមពីលើចង្អូររងប្រវែង២០ម៉ែត្ររួចកាប់ជ្រោយអោយបានសព្វមុនពេលដាំ។
- <u>ការដាក់ជីបំប៉ន:</u> យើងប្រើជីអ៊ុយរ៉េ២ដង និងជី២០-២០-១៥ ១ដងសំរាប់បំប៉នដើមម្នាស់អោយលូតលាស់ល្អ។ ត្រូវសំអាតស្មៅអោយបានស្អាតជាមុនសិន និងត្រូវដាក់ជី



ក្រោយភ្លៀងធ្លាក់ សំរាប់រដូវវស្សា។ នៅរដូវប្រាំងយើងត្រូវយកជីអ៊ុយរ៉េចំនួន កន្លះគីឡូក្រាម លាយទឹក១ធុងចំណុះ២០លីត្រ សំរាប់កូនម្នាស់ ១០០ដើម។ ត្រូវចាក់ស្រោច តាមគល់កុំអោយទឹកជីចូលក្នុងបណ្តួលដើមម្នាស់។



* <u>*លើកទី១:*</u> ត្រូវដាក់ជីក្នុងរយៈពេល១ ខែកន្លះក្រោយដាំ ប្រើជីអ៊ុយរ៉េ ១គក្រសំរាប់កូនម្នាស់ ២០០ ដើម។
* <u>*លើកទី២:*</u> ត្រូវដាក់ជីក្នុងរយៈពេល ២ខែក្រោយលើកទី១ ប្រើជីអ៊ុយរ៉េម្តងទៀត ១គក្រ សំរាប់កូនម្នាស់ ២០០ ដើម។
* <u>*លើកទី៣:*</u> ពេលម្នាស់ចាប់ផ្តើមចេញផ្កា ប្រើជី ២០-២០-១៥ ១គក្រ សំរាប់ កូនម្នាស់ ២០០ ដើម។

- <u>ចំណាំ:</u> យើងអាចប្រើជីទឹកនោម ត្រាំជាមួយលាមកសត្វ និងដើមកន្ទ្រាំងខែត្រ ដោយចាក់ស្រោចតាមគល់ជំនួសជីអ៊ុយរ៉េបាន។ យើងប្រើទឹកជី១ធុងចំណុះ២០លីត្រ សំរាប់ម្នាស់ ១០០ដើម។